ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រៃសណីយ៍កម្ពុជា

លេខ:......០៤៨.......ប.ក

ថ្ងៃ ចន្ទ ១០កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលតម្លៃសេវាប្រៃសណីយ៍ក្នុងប្រទេស

## ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកប្រៃសណីយ៍កម្ពុជា

- បានឃើញព្រះរាជក្រម ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ពីវិស័យប្រៃសណីយ៍
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការបង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.តត ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកប្រៃសណីយ៍កម្ពុជាអាណត្តិទី៤
- បានឃើញអនុក្រឹត្យលេខ ៦៦៩ អនក្រ.តត ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រៃសណីយ៍កម្ពុជាអាណត្តិទី៤
- បានឃើញសេចក្តីសម្រេចលេខ ០៣៤ ប.ក. ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលតម្លៃសេវាប្រៃសណីយ៍
- យោងកំណត់ហេតុអង្គប្រជុំចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២០ ស្តីពី ការជម្រុញដំណើរការសេវាកស្តុភារកម្មនិងជ្រើសរើសភ្នាក់ងារ

## សម្រេច

**ប្រការ១** : ត្រូវបានអនុញ្ញាតឲ្យកែសម្រួល និងដាក់ឲ្យប្រើប្រាស់តម្លៃសេវាប្រៃសណីយ៍របបក្នុងប្រទេសដូចភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ ទី១។

**ប្រការ២** : គ្រប់អគ្គនាយករង នាយកដ្ឋានក្រោមឱវាទ សាខាខេត្ត-ក្រុង នៃប្រៃសណីយ៍កម្ពុជា ព្រមទាំងមជ្ឈមណ្ឌលសាមី ត្រូវអនុវត្តន៍ឲ្យបានម៉ឺងម៉ាត់ នូវសេចក្តីសម្រេចនេះ ។

**ប្រការ៣** : រាល់សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤** : សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២០ នេះតទៅ ។

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយកប្រៃសណីយ៍កម្ពុជា

C.P.

CAMBODIA POST

អោក-បូរ៉ា

**កន្លែងទទួល**

-ក្រុមប្រឹក្សាភិបាល

«ដើម្បីជូនជ្រាប»

-ដូចប្រការ ២

«ដើម្បីអនុវត្តន៍»

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រៃសណីយ៍កម្ពុជា

លេខ:.................................ប.ក

**ឧបសម្ព័ន្ធទី ១**

**ការកែសម្រួលតម្លៃសេវាប្រៃសណីយ៍របបក្នុងប្រទេស**

( សុពលភាពអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២០, តាមសេចក្តីសម្រេចលេខ...០៥៥ ប.ក....... )

ប្រៃសណីយ៍កម្ពុជាកំពុងរៀបចំ បង្កើននិងលើកកំពស់គុណភាពសេវាប្រៃសណីយ៍ក្នុងប្រទេស ឲ្យកាន់តែមានទំនុកចិត្ត ដោយបានបំពាក់នូវប្រព័ន្ធតាមដានបញ្ញើ ចាប់ពីសេវាសំបុត្រមូលដ្ឋានទាបបំផុតនោះឡើង ដោយផ្តល់ឲ្យអតិថិជន នូវលេខកូដតាមដាននៃដំណើរបញ្ញើ ចាប់តាំងពីការដាក់ផ្ញើ ដឹកជញ្ជូន រហូតដល់ចែកបានសម្រេច ឬមូលហេតុផ្សេងៗ ដែលខកខានចែកមិនសម្រេច ។ ដើម្បីអនុវត្តការលើកកំពស់គុណភាពសេវានេះ ប្រៃសណីយ៍កម្ពុជា នឹងធ្វើការកែសម្រួលសេវាកម្ម និងតម្លៃសេវាដូចខាងក្រោម៖

១.កែសម្រួល តម្លៃសេវា សំបុត្រនិងកញ្ចប់បញ្ញើបិទជិត LCAO ក្នុងប្រទេស ៖

- គ្រប់សេវាបញ្ញើប្រៃសណីយ៍ក្នុងប្រទេសទាំងអស់ នឹងត្រូវផ្តល់ស្លាកលេខកូដ តាមដានចូលក្នុងប្រព័ន្ធ
- តម្លៃសេវា សំបុត្រ និងកញ្ចប់បញ្ញើ LCAO ក្នុងប្រទេស ត្រូវបូកបន្ថែមអាករ ផ្ញើជាអនុសិដ្ឋ ចំនួន ១,០០០ រៀល លើគ្រប់បញ្ញើ ។

ឧទាហរណ៍ ៖

- ទម្ងន់រហូតដល់ ៥០ ក្រាម ៨០០ រៀល +១,០០០ រៀល
  (តម្លៃសរុប ត្រូវជា ១,៨០០ រៀល, មានលេខតាមដាន, ពុំមានចុះហត្ថលេខាទទួល)
- បើអតិថិជនមានតម្រូវការចុះហត្ថលេខាពេលទទួល ត្រូវបូកបន្ថែម សេវាឆ្លើយតប AR ៖
  ទម្ងន់រហូតដល់ ៥០ ក្រាម ៨០០ រៀល +១,០០០ រៀល RD+៨០០ រៀល AR
  (តម្លៃសរុប ត្រូវជា ២,៦០០ រៀល, មានលេខតាមដាន, មានហត្ថលេខាពេលទទួល និងជូនដំណឹង)

២.កែសម្រួលតម្លៃសេវា បញ្ញើ EMS ក្នុងប្រទេស ៖

- ការទទួលបញ្ញើ EMS ក្នុងប្រទេស ក្នុងទម្ងន់អប្បរិមាចាប់ពី ចាប់ពី ០.០០ គ.ក្រ ដល់ ០.៥០ គ.ក្រ ឡើង៖

- ទម្ងន់លើសពី ០.០០ គ.ក្រ ដល់ ០.៥០ គ.ក្រ ៨,៧០០ រៀល ✓

**ប្រធានក្រុមប្រឹក្សាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកប្រៃសណីយ៍កម្ពុជា**

**អោក-ប៊ុរ៉ា**

អាសយដ្ឋានកាច់ជ្រុងផ្លូវលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ: (៨៥៥) ២៣ ៧២៥ ៥៣៣

ទូរស័ព្ទ: (៨៥៥) ២៣ ៧២៥ ៩៤៤

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រៃសណីយ៍កម្ពុជា

លេខ:..............................ប.ក

## ឧបសម្ព័ន្ធ

## តារាងតម្លៃសេវាដឹកបញ្ញើភស្តុភារកម្មក្នុងប្រទេស និងលក្ខខណ្ឌ

( សុពលភាពអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២០, តាមសេចក្ដីសម្រេចលេខ ០៥៧ ប.ក )

| កញ្ចប់តាមប្រភេទទម្ងន់ | | តម្លៃសេវាកម្ម (រៀល) | |
|---|---|---|---|
| ទម្ងន់លើសពី | រហូតដល់ | ↩ ចែកក្នុងក្រុងតែ១៦<br>↩ ភ្នំពេញ ⇆ ខេត្ត ៦ | ↩ខេត្ត→ ភ្នំពេញ→ ខេត្ត៦ |
| 0.00 គក្រ | ២.00 គក្រ | ៥,000 | ៨,000 |
| ២.00 គក្រ | ៥.00គក្រ | ១0,000 | ១៦,000 |
| ៥.00 គក្រ | ១0.00 គក្រ | ១៥,000 | ២៤,000 |
| ១0.00 គក្រ | ២0.00 គក្រ | ២0,000 | ៣២,000 |
| លើសពី ២០ គក្រ | តម្លៃក្នុង ១ គក្រ | ១,000 | ១,៦00 |
| រយៈពេល ដឹកជញ្ជូន | ↩ចែកក្នុងក្រុងតែ១៦ | ដាក់ផ្ញើមុនម៉ោង១0.00 ព្រឹក នឹងចែកពេលរសៀល<br>ដាក់ផ្ញើក្រោយម៉ោង១0.00 ព្រឹក នឹងចែកថ្ងៃបន្ទាប់ | មិនមាន |
| | | ↩ ភ្នំពេញ ⇆ ខេត្ត ៦ ចែកថ្ងៃបន្ទាប់ (២៤ ម៉ោង) | ↩ខេត្ត→ ភ្នំពេញ→ ខេត្ត៦ ចែករំលង១ថ្ងៃ(៤៨ម៉ោង) |

គុណសម្បត្តិ នៃសេវាកម្ម បញ្ញើភស្តុភារកម្ម ក្នុងប្រទេស ៖

- ផ្ដល់លេខតាមដានដំណើរបញ្ញើ តាំងពីការដាក់ផ្ញើ រហូតដល់គោលដៅ ប៉ុន្តែពុំមានហត្ថលេខាអ្នកទទួលទេ ។

១-ចំពោះការដាក់ផ្ញើបញ្ញើទៅខេត្តឆ្ងាយ

- អតិថិជនមកដាក់ផ្ញើនៅតាមសាខាប្រៃសណីយ៍កម្ពុជា រាជធានី/ខេត្តក្រុង ហើយជ្រើសរើសសាខាគោលដៅដែលត្រូវទទួលដែលមានបញ្ជីសាខា ដាក់ឲ្យជ្រើសរើសតាមតំបន់ដែលប្រកាសដែនសុពលភាពទៅដល់ នៅតាមថ្ងៃការងារ ។

២-ចំពោះការដាក់ផ្ញើនៅក្នុងតំបន់តែមួយ (ក្នុង ក្រុង ឬរាជធានី)

- អតិថិជនមកដាក់ផ្ញើនៅ តាមសាខាប្រៃសណីយ៍កម្ពុជា រាជធានី/ខេត្តក្រុង ភ្នាក់ងារប្រៃសណីយ៍ នឹងចែកទៅដល់ គោលដៅអាសយដ្ឋាន ។

៣-ការធានាទូទាត់សងចំពោះការបាត់បង់ នៃសេវាកម្មបញ្ញើភស្តុភារកម្ម ក្នុងប្រទេស៖

- ការបាត់បញ្ញើបញ្ញើភស្តុភារកម្ម ក្នុងប្រទេស ត្រូវទូទាត់សងចំពោះអ្នកផ្ញើ ស្មើនឹង ១០ ដងនៃតម្លៃបញ្ញើ ។
- ប្រសិនបើអតិថិជនដាក់ប្រកាសតម្លៃនៃអន្តរវត្ថុបញ្ញើ អតិថិជនត្រូវបង់ថ្លៃសេវាប្រកាស ៣.៥% នៃថ្លៃប្រកាស ហើយ ការទូទាត់សំណង នឹងត្រូវសងសរុប ១០០% នៃតម្លៃដែលបានប្រកាស ។

| តម្លៃទំនិញ ឬបញ្ញើ/សង១00% | + សេវាប្រកាសតម្លៃ ៣.៥% | តម្លៃសេវាផ្ញើ | អតិថិជនត្រូវបង់សរុប |
|---|---|---|---|
| ១,000,000 រៀល | ៣៥,000 រៀល | ៥,000 រៀល | ៤0,000 រៀល |

ប្រធានក្រុមប្រឹក្សាភិបាល

ឧត្តមប្រឹក្សាអគ្គនាយកប្រៃសណីយ៍កម្ពុជា

CAMBODIA POST

អោក-បូរ៉ា